**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...៧៤៩.....អបស/ប្រកស

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧...

# ប្រកាស

## ស្តីពី

## ការផ្តល់វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៤១៦/៣៦៤ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០០ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញប្រកាសអន្តរក្រសួងលេខ៨៦៨ ឧក.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍និងរៀបចំសម្របសម្រួលស្តាប់នៃកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារតាមបំពីកសិដ្ឋានផលិត ដល់តុបរិភោគ
- តាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ ១.**

ប្រកាសនេះមានគោលបំណងផ្តល់វិញ្ញាបនបត្របញ្ជាក់ពីអនាម័យ និងសុវត្ថិភាពផលិតផលចំណីអាហាររួមមាន:

- វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ (Certificate of Free Sales)
- វិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារ (Health Certificate)

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះផលិតផលចំណីអាហារផលិតក្នុងព្រះរាជាណាចក្រកម្ពុជា ឬនាំចូលពីបរទេសដើម្បីធ្វើចរាចរលក់លើទីផ្សារក្នុងប្រទេស ឬនាំចេញទៅបរទេសដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវប្រទេសនាំចូល។

**ប្រការ ៣.-**

**ក.វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ** (Certificate of Free Sales): គឺជាលិខិតចេញដោយក្រសួងសុខាភិបាលដើម្បីបញ្ជាក់ពីអនាម័យនិងសុវត្ថិភាពនៃផលិតផលចំណីអាហារដែលនាំចូល ឬផលិតក្នុងប្រទេស និងអាចដាក់លក់នៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជាបាន។

**ខ.វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ** (Health Certificate): គឺជាលិខិតចេញដោយក្រសួងសុខាភិបាល ដើម្បីបញ្ជាក់ពីអនាម័យ និងសុវត្ថិភាពនៃផលិតផលចំណីអាហារសម្រាប់នាំចេញទៅបរទេស។ លិខិតនេះក៏បញ្ជាក់ផងដែរពីអនុលោមភាពនៃគ្រឹះស្ថានផលិត រោងចក្រផលិត ឬក្រុមហ៊ុននាំចេញផលិតផលចំណីអាហារ ទៅនឹងលិខិតបទដ្ឋានគតិយុត្តរបស់ប្រទេសផលិត ហើយឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវរបស់ប្រទេសនាំចូល។

**ប្រការ ៤.-**

ម្ចាស់គ្រឹះស្ថានផលិត រោងចក្រផលិត ឬក្រុមហ៊ុននាំចេញ នាំចូលផលិតផលចំណីអាហារទាំងអស់ត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារសម្រាប់ការធ្វើចរាចរផលិតផលចំណីអាហារនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ឬត្រូវស្នើសុំវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារសម្រាប់ការនាំចេញទៅបរទេស ពីក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យនិងគ្រឿងសំអាង)។

**ប្រការ ៥.-**

ម្ចាស់គ្រឹះស្ថានផលិត រោងចក្រផលិត ឬក្រុមហ៊ុននាំចេញ នាំចូលផលិតផលចំណីអាហារ ត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្របញ្ជាក់អនាម័យផលិតផលចំណីអាហារ នូវពាណិជ្ជនាមផ្សេងទៀតដោយរក្សារូបមន្តដដែលតម្រូវតាមការទាមទាររបស់ប្រទេសនាំចូល។

**ប្រការ ៦.-**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ មានដូចខាងក្រោមៈ

- ពាក្យស្នើសុំ (មានគំរូ)

- លិខិតអនុញ្ញាតបើកគ្រឹះស្ថានផលិត រោងចក្រផលិត ឬក្រុមហ៊ុននាំចូល នាំចេញផលិតផលចំណីអាហារដែលចេញដោយការបញ្ជាក់ពីក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ
- បណ្ណាគារដែលស្ថិតក្នុងសុពលភាព(ចំពោះផលិតផលក្នុងស្រុក អនុវត្តតាមប្រកាសលេខ៥០៣សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ(GMP) ឬ HACCP Certificate ឬ ISO - 22000 ឬវិញ្ញាបនបត្រសមមូល
- វិញ្ញាបនបត្រវិភាគពីរោងចក្រផលិត (Certificate of Analysis)
- វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ (Free Sales Certificate / Health Certificate) ពីប្រទេសផលិត ឬប្រទេសដែលកំពុងដាក់លក់ផលិតផលចំណីអាហារនោះ (មិនអនុវត្តចំពោះផលិតផលក្នុងស្រុកទេ)
- គំរូសាកផលិតផលចំនួន ៥ ឯកតា (Samples 5 units)

**ប្រការ ៧.**

ចំពោះសោហ៊ុយសេវាត្រូវកំណត់តាមប្រកាសរួមរវាងក្រសួងសុខាភិបាលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៨.**

វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ (Certificate of Free Sales) និងវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ (Health Certificate) មានសុពលភាពរយៈពេល០១ឆ្នាំ។

**ប្រការ ៩.**

ក្រសួងសុខាភិបាលនឹងផ្តល់វិញ្ញាបនបត្រទាំងពីរខាងលើជូនគ្រឹះស្ថានផលិត រោងចក្រផលិត ឬក្រុមហ៊ុននាំចេញ នាំចូលផលិតផលចំណីអាហារ ក្នុងរយៈពេល៣០ថ្ងៃ (ថ្ងៃធ្វើការ ) បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់។

**ប្រការ ១០.**

ក្នុងករណីដែលរកឃើញ ឬមានការប្រកាសអាសន្នពីអាជ្ញាធរមានសមត្ថកិច្ចថាផលិតផលចំណីអាហារនោះ គ្មានសុវត្ថិភាព ឬប៉ះពាល់ដល់សុខភាពអ្នកបរិភោគ ក្រសួងសុខាភិបាលមានសិទ្ធិព្យួរ ឬដកហូតវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារដែលចេញដោយក្រសួងសុខាភិបាល។ ក្នុងករណីនេះ ម្ចាស់គ្រឹះស្ថានផលិត រោងចក្រផលិត ឬក្រុមហ៊ុននាំចេញ នាំចូលផលិតផលចំណីអាហារត្រូវប្រមូលត្រឡប់មកវិញនូវផលិតផលចំណីអាហារទាំងនោះ និងត្រូវសហការឱ្យបានល្អជាមួយក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធ។

**ប្រការ ១១.**

ប្រកាសលេខ ១៦៥អបស.ជអបស ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ស្តីពីការផ្តល់វិញ្ញាបនបត្រ

អនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ និងការផ្តល់វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២.-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ អគ្គនាយកបច្ចេកទេសសុខាភិបាល ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត មានភារកិច្ចណែនាំត្រួតពិនិត្យការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ម៉ម ប៊ុនហេង

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីសហការ
- សាលារាជធានី-ខេត្ត
- ដូចប្រការ១២
- គ្រឹះស្ថាន-រោងចក្រផលិត ក្រុមហ៊ុននាំចេញ នាំចូលផលិតផលចំណីអាហារ "ដើម្បីអនុវត្តន៍"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ